**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ១០៧/២៤ ក.ប/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ
## ស្តីពី
## ការឈប់សម្រាកដោយមានប្រាក់ឈ្នួលក្នុងឱកាសចូលរួមអបអរសាទរ ការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤

យោងតាមសារាចរលេខ១១ សរ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាល ស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការ បុគ្គលិក កម្មករ និយោជិត និងសិស្ស និស្សិត ឈប់សម្រាកក្នុងឱកាសចូលរួមអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ និងសេចក្តីណែនាំលេខ ១០៣/២៤ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការវាយគង ជួង រគាំង ទូងស្គរ ទះប៉ោត និងគោះត្រដោកនៅតាមសហគ្រាស គ្រឹះស្ថាន ដើម្បីអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ក្រសួងសូមណែនាំដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ ដូចខាងក្រោម៖

- ត្រៀម និងរៀបចំសម្ភារចាំបាច់នានា ដើម្បីធ្វើការផ្សាយបន្តផ្ទាល់នូវសំឡេងនិងទស្សនីយភាពនៃពិធីផ្លូវការនៃការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ចាប់ពីម៉ោង ៧:២០នាទីព្រឹក និងធ្វើការវាយគង ជួង រគាំង ទូងស្គរ ទះប៉ោត និងគោះត្រដោក នៅវេលាម៉ោង ៩:០៩នាទីព្រឹក នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤
- រៀបចំឱ្យមានកម្មវិធីកម្សាន្តផ្សេងៗ នៅក្នុងបរិវេណសហគ្រាស គ្រឹះស្ថានតាមលទ្ធភាពជាក់ស្តែង
- អនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់បានឈប់សម្រាកនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ បន្ទាប់ពីបានចូលរួមអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោជាផ្លូវការនៅតាមសហគ្រាស គ្រឹះស្ថានរៀងៗខ្លួនរួចមក។

អាស្រ័យដូចបានជម្រាបជូនខាងលើ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ អញ្ជើញចូលរួមកម្មវិធីអបអរសាទរនេះ នៅតាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួនស្របតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យបានត្រឹមត្រូវ និងផ្សព្វផ្សាយនូវសកម្មភាពចូលរួមអបអរសាទរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ឱ្យបានផុលផុស។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ